# ការអនុវត្តជាក់ស្តែងនៃ
# ការបែងចែកមត៌ក II

មេធាវី  តូយ៉ាម៉ា ហ្វឹតូស៊ី
Toyama Futoshi, Attorney at law

# ការធ្វើលិខិតពាក្យសុំដីកាសម្រេចបែងចែកមត៌ក

- សមត្ថកិច្ចតុលាការ
- អ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត (ការកំណត់អំពីសន្តតិជន)
- តើមេធាវីជាតំណាងឲ្យអ្នកណា? (លទ្ធភាពដែលអាចមានភាពផ្ទុយគ្នានៃផលប្រយោជន៍ និង ការខូចខាត)
- អាសយដ្ឋានរបស់មតកជននៅពេលទទួលមរណភាព
- អត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍
- មានការព្រមព្រៀង(ការព្រមព្រៀងរបស់សន្តតិជនទាំងអស់) អំពីវិធីនៃការបែងចែកមត៌ក
- ឯកសារបញ្ជាក់ដំបូង
- បញ្ជីសារពើភ័ណ្ឌស្តីពីមត៌ក

# ករណីសិក្សា1៖ ករណីដែលមានសន្តតិជនជំនួស

- ករណីសិក្សាដែលក្មួយរបស់មតកជននឹងត្រូវក្លាយជាសន្តតិជនជំនួស នៅក្នុងឧទាហរណ៍ សន្តតិជនមានប្រពន្ធ និងបងប្អូន ហើយនៅក្នុងចំណោមបងប្អូនទាំងនោះ មានអ្នកដែលបានទទួលមរណភាព
- ទំនាក់ទំនងអង្គហេតុ
  - មតកជន A បានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ B ប៉ុន្តែ អ្នកទាំងពីរមិនបានមានកូនទេ។
  - នៅពេលដែល A បានទទួលមរណភាព ឪពុក C និងម្ដាយ D របស់គាត់បានទទួលមរណភាពមុនរួចហើយ។
  - ក្នុងចំណោមបងប្អូនរបស់ A មានបងប្រុស E ដែលបានកើតចេញពីឪពុក C និងម្ដាយ D ព្រមទាំងមានប្អូនស្រីG ដែលបានកើតចេញពីផ្ទៃខុសគ្នា រវាងពីឪពុក C និងប្រពន្ធមុន F ។
  - នៅពេលដែល Aទទួលមរណភាព E បានទទួលមរណភាពមុនបាត់ទៅហើយ ហើយ E មានកូនចំនួន៣នាក់ គឺ H I និង J ។
  - មត៌ករបស់ A រួមមានអចលនវត្ថុដែលជាផ្ទះរបស់ខ្លួនឯង ព្រមទាំងសាច់ប្រាក់ ហើយ B ធ្វើលទ្ធកម្មនូវអចនលវត្ថុនោះ រីឯសន្តតិជនផ្សេងទៀតធ្វើលទ្ធកម្មនូវសាច់ប្រាក់ផ្អែកតាមភាគនៃចំណែកមត៌កតាមច្បាប់កំណត់។

# ករណីសិក្សា1៖ ករណីដែលមានសន្តតិជនជំនួស

- ការកំណត់អំពីសន្តតិជន
- ការផ្ទៀងផ្ទាត់អំពីចំណែកមត៌កតាមច្បាប់

- ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ
  - 1. B ធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។
  - 2.  H I J និង G ធ្វើលទ្ធកម្មនូវសាច់ប្រាក់ចំនួន ១៨,000ដុល្លារទៅតាមចំណែករៀងៗខ្លួន ដោយ H ចំនួន៤000ដុល្លារ   I ចំនួន៤000ដុល្លារ  J ចំនួន៤000ដុល្លារ   និង G ចំនួន៦000ដុល្លារ។




① ចំណែកសន្តតិកម្មរបស់ប្រពន្ធ B គឺ១/២
(CC មាត្រា ១១៦២ ចំណុច គ )

B: $៣៦.000 X ១/២ = $១៨.000

② G គឺជាសន្តតិជន (CC មាត្រា ១១៦០ (កថា.ទី១)) ចំណែកសន្តតិកម្មរបស់ G គឺ ១/៦(១/២ X ១/៣)(CC មាត្រា១១៦០ (កថា.ទី២) វាក្យខណ្ឌទី២))។

G: $៣៦.000 X ១/៦ = $៦.000

③ H,I និង J គឺជាសន្តតិជន (CC មាត្រា ១១៦០ (កថា.ទី៣) មាត្រា ១១៥៧ (កថា.ទី១) ចំណែកសន្តតិកម្មរបស់ពួកគេម្នាក់ៗ គឺ១/៩ (១/២X២/៣X១/៣) (CC មាត្រា ១១៦០ (កថា.ទី៣) មាត្រា ១១៥៨)។

H: $៣៦.000 X ១/៩ = $៤.000
I: $៣៦.000 X ១/៩ = $៤.000
J: $៣៦.000 X ១/៩ = $៤.000

- មត៌ក:$៣៦.000
- អចលនវត្ថុ : $១៨.000
- សាច់ប្រាក់:$១៨.000




A និង E ជាបងប្អូនដែលមានឪពុកម្ដាយតែមួយ។ ប៉ុន្តែ A និង G ជាបងប្អូនដែលមានឪពុកដូចគ្នា ម្ដាយខុសគ្នា។ ដូចនេះ ចំណែកសន្តតិកម្មរបស់ G នឹងក្លាយជាចំណែកសន្តតិកម្មរបស់ E ពាក់កណ្ដាល។

# ករណីសិក្សា 2 ៖ ករណីដែលមានអនីតិជននៅក្នុងចំណោមសន្តតិជន ហើយអ្នកមានអំណាចមេបាលើអនីតិជននោះ ក៏ជាសន្តតិជន

- ករណីសិក្សាដែលប្រពន្ធ និង កូនដែលជាអនីតិជន នឹងត្រូវក្លាយជាសន្តតិជន
- ទំនាក់ទំនងអង្គហេតុ
  - មតកជន A  បានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ B   ហើយអ្នកទាំងពីរមានកូនចំនួន ២នាក់ គឺ C និង D ។ A ពុំមានកូនផ្សេងទៀតឡើយ។ មត៌ករបស់ A មានដូចជា អចលនវត្ថុដែលជាផ្ទះរបស់ខ្លួនឯង (ផ្ទះដែល A បានទទួលសន្តតិកម្មពីឪពុក) និង ប្រាក់បញ្ញើក្នុងធនាគារ។
  - ដោយសារតែ A បានទទួលមរណភាពទាំងនៅវ័យក្មេងនៅឡើយ   ហេតុនេះ នៅពេល A ទទួលមរណភាព C មានអាយុ ១៧ ឆ្នាំ  D មានអាយុ ១០ ឆ្នាំ ក្រោយពី A បានទទួលមរណភាពមិនទាន់បានប៉ុន្មានផង C បានគ្រប់អាយុ ១៨ ឆ្នាំ។
  - ដោយសារតែ តម្លៃនៃការវាយតម្លៃចំពោះអចលនវត្ថុ គឺប្រហែល១ភាគ២នៃតម្លៃប្រាក់បញ្ញើក្នុងធនាគារ    ហេតុនេះ B ធ្វើលទ្ធកម្មនូវផ្ទះនោះ  រីឯ C និង D ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើក្នុងធនាគារ ដោយម្នាក់ៗទទួលបានចំនួន១ភាគ២ ។  ម្យ៉ាងវិញទៀត ដោយសារតែ E ត្រូវបានជ្រើសតាំងជាអ្នកតំណាងពិសេសឲ្យ D  ហេតុនេះ E ក៏យល់ព្រមតាមខ្លឹមសារនៃការបែងចែកនេះដែរ។

# ករណីសិក្សា 2 ៖ ករណីដែលមានអនីតិជននៅក្នុងចំណោមសន្តតិជន ហើយអ្នកមានអំណាចមេបាលើអនីតិជននោះ ក៏ជាសន្តតិជន

- ការជ្រើសតាំងអ្នកតំណាងពិសេស
- ករណីគ្រប់នីតិភាពនៅពេលដែលធ្វើការបែងចែកមត៌ក
- ករណីសន្តតិជនដែលជាអនីតិជនមានចំនួនច្រើននាក់
- ការសរសេរអំពីភាគីនៅលើពាក្យសុំដីកាសម្រេចបែងចែកមត៌ក

# ករណីសិក្សា3 ៖ ករណីបង់ប្រាក់សម្រួលហើយធ្វើការបែងចែក

- ការបែងចែកវត្ថុ គឺជាគោលការណ៍ ប៉ុន្តែ ក្នុងករណីលើកលែង ក៏អាចបង់ប្រាក់សម្រួលហើយធ្វើការបែងចែកបានផងដែរ (CC មាត្រា១២៦៧ កថា.ទី២)
- ទំនាក់ទំនងអង្គហេតុ
  - មតកជន A មិនមានប្តីទេ  ហើយគាត់រស់នៅក្នុងផ្ទះជាមួយកូនស្រីច្បង B ។
  - A នៅមានកូនប្រុសច្បង C ម្នាក់ផ្សេងទៀត។
  - មត៌ករបស់ A មានតែដី និង ផ្ទះនោះតែប៉ុណ្ណោះ។
  - ផ្អែកតាមលទ្ធផលនៃការពិភាក្សារវាង B និង C  B ត្រូវធ្វើលទ្ធកម្មនូវផ្ទះនោះ  ហើយត្រូវបង់ប្រាក់សម្រួលទៅឲ្យ C ។

# ករណីសិក្សា3 ៖ ករណីបង់ប្រាក់សម្រួលហើយធ្វើការបែងចែក

- ករណីដែលការបែងចែកដោយបង់ប្រាក់សម្រួលត្រូវបានទទួលស្គាល់ គឺជា...
- ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ
  - 1. B ធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។
  - 2. B ត្រូវទទួលបន្ទុកចំពោះកាតព្វកិច្ចជាប្រាក់ចំនួន..........រៀលដែលជាប្រាក់សម្រួលដើម្បីការធ្វើលទ្ធកម្មនូវមត៌កដូចដែលបានលើកឡើងក្នុងចំណុចទី១. ហើយត្រូវបង់ឲ្យទៅ C ត្រឹមថ្ងៃទី.... ខែ..... ឆ្នាំ............។

# ករណីសិក្សា 4 ៖ ករណីដែលភាគីត្រូវបង់រំលោះចំពោះការបង់ប្រាក់សម្រួល ហើយបានបង្កើតហ៊ីប៉ូតែកដើម្បីធានានូវការបង់ប្រាក់នោះ

- ទំនាក់ទំនងអង្គហេតុ
  - នៅក្នុងករណីសិក្សា 3 B ធ្វើលទ្ធកម្មនូវផ្ទះនោះ ហើយត្រូវបង់ប្រាក់សម្រួលឲ្យទៅC ប៉ុន្តែ នៅក្នុងករណីសិក្សា 4 វិញ  ដោយសារតែ B មិនអាចរៀបចំសាច់ប្រាក់ទាំងអស់នៃប្រាក់សម្រួលនោះបានភ្លាមៗទេ ក៏សម្រេចថាបង់រំលោះប្រាក់សម្រួល ហើយបង្កើតហ៊ីប៉ូតែកលើផ្ទះដែល B បានធ្វើលទ្ធកម្មនោះ ដើម្បីធានានូវការបង់ប្រាក់។

# ករណីសិក្សា 4 ៖ ករណីដែលភាគីត្រូវបង់រំលោះចំពោះការបង់ប្រាក់សម្រួល ហើយបានបង្កើតហ៊ីប៉ូតែកដើម្បីធានានូវការបង់ប្រាក់នោះ

- ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ
  - 1. B ធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្ដីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ។
  - 2. B ត្រូវទទួលបន្ទុកចំពោះកាតព្វកិច្ចជាប្រាក់ចំនួន........រៀល ដែលជាប្រាក់សម្រួលដើម្បីធ្វើលទ្ធកម្មនូវមត៌កដូចលើកឡើងក្នុងចំណុចទី១ ហើយត្រូវបង់រំលោះភាគនីមួយៗចំនួន..........រៀល នៅថ្ងៃចុងក្រោយជារៀងរាល់ខែ ដោយគិតចាប់ពីខែ.......ឆ្នាំ.......... ដល់ខែ...... ឆ្នាំ..........។
  - 3. B ត្រូវបង្កើតហ៊ីប៉ូតែកលំដាប់ទី១ ដែលមានកាតព្វកិច្ចចំនួន...........រៀលលើអចលនវត្ថុដែលបានសរសេរក្នុងចំណុចទី១ ដើម្បីធានានូវការបង់ប្រាក់ដូចដែលបានលើកឡើងក្នុងចំណុចទី២ ដោយយក C ជាម្ចាស់បំណុល ហើយត្រូវធ្វើនីតិវិធីចុះបញ្ជីនោះ។ ប៉ុន្តែ សោហ៊ុយសម្រាប់ការធ្វើនីតិវិធីនៃការចុះបញ្ជី គឺជាបន្ទុករបស់ B។

# ករណីសិក្សា 5 ៖ ករណីធ្វើការបែងចែងនូវប្រាក់ថ្លៃលក់ដែលបានពីការប្តូរអចលនវត្ថុជាប្រាក់

- ទំនាក់ទំនងអង្គហេតុ
  - សន្តតិជនរបស់មតកជន A មានកូនប្រុសច្បង B និងកូនស្រីច្បង C។ មត៌ករបស់A មាន ដី និង ផ្ទះ ដែលស្ថិតនៅក្នុងក្រុងបាត់ដំបង រួមទាំងប្រាក់បញ្ញើនៅក្នុងធនាគារ។ ដោយសារតែទាំង B និង C សុទ្ធតែមានកម្មសិទ្ធិលើផ្ទះនៅក្រុងភ្នំពេញរៀងៗខ្លួន ហេតុនេះ ពួកគេមិនមានបំណងធ្វើលទ្ធកម្មនូវ ដី និង ផ្ទះដែលស្ថិតនៅក្នុងក្រុងបាត់ដំបងនោះទេ។ ដូចនេះ ពួកគេក៏បានលក់អចលនវត្ថុនេះទៅឲ្យតតិយជន និងបានព្រមព្រៀងគ្នាថា នឹងបែងចែកនូវប្រាក់នៅសល់បន្ទាប់ពីបានដកសម្រាប់សោហ៊ុយនៃការលក់។ ម៉្យាងវិញទៀត ដោយសារតែកូនស្រីច្បងក្រីក្រ ហើយត្រូវការប្រាក់ជាចាំបាច់ ដូច្នេះ ចំពោះប្រាក់បញ្ញើក្នុងធនាគារនឹងត្រូវធ្វើការបែងចែកឲ្យខុសពីចំណែកមត៌កដែលច្បាប់បានកំណត់ ដោយ B ត្រូវធ្វើលទ្ធកម្មចំនួន ១ ភាគ ៣ ហើយ C ត្រូវធ្វើលទ្ធកម្មចំនួន ២ ភាគ ៣ នៃប្រាក់បញ្ញើនោះ ។

# ករណីសិក្សា 5 ៖ ករណីធ្វើការបែងចែកនូវប្រាក់ថ្លៃលក់ដែលបានពីការប្តូរអចលនវត្ថុជាប្រាក់

- ករណីដែលអាចធ្វើការបែងចែកដោយប្តូរជាប្រាក់ (CC មាត្រា១២៧១) គឺជា.........
- វិធីនៃការប្តូរជាប្រាក់ (វិធីដែលធ្វើឡើងដោយតុលាការ វិធីដែលធ្វើឡើងតាមការស្ម័គ្រចិត្តរបស់គូភាគី វិធីមុនការចេញដីកាសម្រេច)
- ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ
  - 1. B និង C ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ដោយ B ទទួលបានចំនួន ១ ភាគ ៣ ហើយ C ទទួលបានចំនួន ២ ភាគ ៣។
  - 2. B និង C រួមគ្នាលក់នូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ហើយបន្ទាប់ពីបានដកសោហ៊ុយដែលចាំបាច់សម្រាប់ការលក់ពីប្រាក់នៃការលក់នោះរួច ប្រាក់ដែលនៅសល់ B និង C ត្រូវធ្វើលទ្ធកម្មដោយចំណែកស្មើគ្នា។

# ករណីសិក្សា 5 ៖ ករណីធ្វើការបែងចែកនូវប្រាក់ថ្លៃលក់ដែលបានពីការប្ដូរអចលនវត្ថុជាប្រាក់

- ចំណុចដែលត្រូវប្រុងប្រយ័ត្នក្នុងករណីដែលត្រូវធ្វើការប្ដូរជាប្រាក់ដោយការលក់តាមការស្ម័គ្រចិត្តរបស់គូភាគី
- ឧទាហរណ៍នៃការកំណត់អំពីវិធីប្ដូរជាប្រាក់
  - ឧទា1 ៖ B និង C ត្រូវលក់ឲ្យទៅអ្នកទិញ.........ក្នុងតម្លៃ.........រៀល ត្រឹមថ្ងៃទី......... ខែ......... ហើយធ្វើលទ្ធកម្មដោយចំណែកស្មើគ្នានូវចំនួនទឹកប្រាក់ដែលនៅសល់ពីប្រាក់ថ្លៃលក់ ក្រោយពីបានកាត់សោហ៊ុយដែលចាំបាច់សម្រាប់ចំណាយលើការលក់នោះ។ (ករណីដែលបានកំណត់អំពីអ្នកទិញរួចរាល់)
  - ឧទា2 ៖ B និង C ត្រូវលក់ក្នុងតម្លៃចាប់ពី..........រៀល ត្រឹមថ្ងៃទី......ខែ........ ហើយធ្វើលទ្ធកម្មដោយចំណែកស្មើគ្នានូវចំនួនទឹកប្រាក់ដែលនៅសល់ពីប្រាក់ថ្លៃលក់ ក្រោយពីបានកាត់សោហ៊ុយសម្រាប់អន្តរការីដែលបានណែនាំអចលនវត្ថុ សោហ៊ុយនៃការគ្រប់គ្រងអចលវត្ថុនេះដែលបានកើតឡើងរហូតមកដល់ពេលលក់ និងពន្ធ រួមទាំងសោហ៊ុយនៃការវាយតម្លៃដែលចាំបាច់ដើម្បីការលក់។ (ករណីដែលមិនទាន់បានកំណត់អ្នកទិញ ប៉ុន្តែ បានដឹងច្បាស់អំពីសោហ៊ុយដែលត្រូវកាត់ពីប្រាក់ថ្លៃលក់)

# ករណីសិក្សា 6 ៖ ករណីសិក្សាដែលគូភាគីនឹងត្រូវមានកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ហើយបានព្រមព្រៀងគ្នាអំពីវិធីបែងចែកការគ្រប់គ្រង និង ការអាស្រ័យផលសម្រាប់ពេលក្រោយ

- ទំនាក់ទំនងអង្គហេតុ
  - មតកជន A មានកម្មសិទ្ធិលើ Apartment សម្រាប់ជួល (សរុបចំនួន ១០ យូនីត)។ ប្រពន្ធរបស់គាត់បានទទួលមរណភាពបាត់ហើយ ហើយកូនរបស់គាត់មានចំនួន២នាក់គឺ កូនប្រុសច្បង B និង កូនប្រុសទី២ C។ មត៌ករបស់គាត់មានតែ Apartment នេះប៉ុណ្ណោះ។ B និង C បានព្រមព្រៀងគ្នាថា នឹងទទួលកម្មសិទ្ធិអវិភាគលើភាគនៃចំណែក Apartment ចំនួន ១ភាគ២ ក្នុងម្នាក់ៗ ហើយនៅពេលនោះ ក៏បានព្រមព្រៀងគ្នាសរុបទាំងវិធីបែងចែកចំណូលនៃថ្លៃឈ្នួល នឹងវិធីទទួលបន្ទុកចំពោះសោហ៊ុយក្នុងការគ្រប់គ្រងនៅពេលក្រោយផងដែរ ។

# ករណីសិក្សា 6 ៖ ករណីសិក្សាដែលគូភាគីនឹងត្រូវមានកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ហើយបានព្រមព្រៀងគ្នាអំពីវិធីបែងចែកការគ្រប់គ្រង និង ការអាស្រ័យផលសម្រាប់ពេលក្រោយ

- ករណីដែលការបែងចែកកម្មសិទ្ធិអវិភាគ មានភាពត្រឹមត្រូវ គឺជា............
- ការព្រមព្រៀងអំពីវិធីគ្រប់គ្រង និង ប្រើប្រាស់លើអចលនវត្ថុកម្មសិទ្ធិអវិភាគនៅក្រោយពេលនៃការបែងចែកមត៌ក
- ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ
  - 1 B និង C ធ្វើលទ្ធកម្មចំនួន១ ភាគ ២ក្នុងម្នាក់ៗ លើភាគនៃចំណែករបស់អចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។

# ករណីសិក្សា 6 ៖ ករណីសិក្សាដែលគូភាគីនឹងត្រូវមានកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ហើយបានព្រមព្រៀងគ្នាអំពីវិធីបែងចែកការគ្រប់គ្រង និង ការអាស្រ័យផលសម្រាប់ពេលក្រោយ

- ការព្រមព្រៀងអំពីវិធីគ្រប់គ្រង និង ប្រើប្រាស់លើអចលនវត្ថុកម្មសិទ្ធិអវិភាគនៅក្រោយពេលនៃការបែងចែកមត៌ក (ការព្រមព្រៀងក្រៅផ្លូវតុលាការ)
  - 1. B និង C ត្រូវទទួលទាំងស្រុងនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីកម្មវត្ថុនៃរឿងក្តីនេះ (តទៅនេះហៅថា "អចលនវត្ថុនៃរឿងក្តីនេះ។) ហើយត្រូវយកមកធ្វើជំនួញដោយការជួលដូចមានរហូតមក ។ B និង C នឹងមិនត្រូវកាន់កាប់ និង ប្រើប្រាស់នូវអចលនវត្ថុនៃរឿងក្តីនេះទាំងស្រុង ឬ មួយផ្នែកដោយខ្លួនឯង ឬ មិនឲ្យតតិយជនកាន់កាប់ និង ប្រើប្រាស់បានឡើយ បើពុំមានការព្រមព្រៀងនេះ។
  - 2. កិច្ចការចម្បងដូចជា អន្តរការីសម្រាប់ការបង្កើតភតិសន្យាទាក់ទងនឹងអចលនវត្ថុនៃរឿងក្តីនេះ ការបែងចែកប្រាក់ចំណូល ការបង់ចំណាយលើសោហ៊ុយ ការគ្រប់គ្រងនិងថែរក្សា និង ជំនួញលើការជួលផ្សេងទៀត ជាកិច្ចការដែល B និង C បានពឹងឲ្យភ្នាក់ងារអចលនវត្ថុជាអ្នកធ្វើ ។ ការជ្រើសតាំងភ្នាក់ងារអចលនវត្ថុ និង ខ្លឹមសារនៃអាណត្តិនោះ ត្រូវកំណត់ក្នុងចំណុចបន្ទាប់តាមលេខនីមួយៗ ឬ ត្រូវកំណត់ដោយការពិភាក្សានៅពេលក្រោយ។

# ករណីសិក្សា 6 ៖ ករណីសិក្សាដែលគូភាគីនឹងត្រូវមានកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ហើយបានព្រមព្រៀងគ្នាអំពីវិធីបែងចែកការគ្រប់គ្រង និង ការអាស្រ័យផលសម្រាប់ពេលក្រោយ

- 3. B និង C ព្រមព្រៀងគ្នាដូចខាងក្រោមទាក់ទងនឹងការគ្រប់គ្រងជំនួញលើការជួលអចលនវត្ថុនៃរឿងក្ដីនេះ ៖
  - (1)B និង C ធ្វើលទ្ធកម្មលើប្រាក់ចំណូលដែលបានពីការជួលអចលនវត្ថុនៃរឿងក្ដីនេះដោយចំណែកស្មើគ្នា ហើយចំពោះសោហ៊ុយដែលកើតមានពីការធ្វើលទ្ធកម្មលើប្រាក់ចំណូលនេះ B និង C ត្រូវទទួលបន្ទុកដោយចំណែកស្មើគ្នា។
  - (2) ថ្លៃឈ្នួលដែល B និង C ត្រូវប្រមូលបាន និងប្រាក់ផ្សេងទៀតបានទទួលពីភតិកៈ ភ្នាក់ងារអចលនវត្ថុត្រូវប្រមូលយកហើយប្រើប្រាស់សម្រាប់ការកាត់សោហ៊ុយដែលត្រូវចំណាយសរុបជាប្រចាំ ហើយប្រាក់ដែលនៅសល់ត្រូវឲ្យផ្ញើចូលទៅតាមគណនីធនាគាររៀងៗខ្លួនរបស់ B និង C ដែលបានចង្អុលបង្ហាញ។

# សូមអរគុណ